MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**ទិវាលទ្ធិប្រជាធិបតេយ្យអន្តរជាតិ - ថ្ងៃព្រហស្បតិ៍ ទី១៥ ខែកញ្ញា ឆ្នាំ២០១៦**

# "ច្រើនលើសពីការដែលគ្រាន់តែបោះឆ្នោតតាមកាលកំណត់" - អ្នកជំនាញការឯករាជ្យរបស់ អ.ស.ប បាន អំពាវនាវឲ្យអនុវត្តលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់បន្ថែមទៀត នៅទូទាំងពិភពលោក

ទីក្រុងហ្សឺណែវ (១៤ ខែកញ្ញា ឆ្នាំ២០១៦) - *ថ្លែងនៅមុនទិវាលទ្ធិប្រជាធិបតេយ្យអន្តរជាតិ អ្នកជំនាញការឯករាជ្យរបស់ អ.ស.ប ទទួលបន្ទុកការលើកកម្ពស់សណ្ដាប់ធ្នាប់អន្តរជាតិ ប្រកបដោយសមធម៌ និងប្រជាធិបតេយ្យ លោក អាលហ្វ្រិដ ដឺ ហ្សាយ៉ាស់ អំពាវនាវឲ្យសភា និងរដ្ឋាភិបាល ឆ្លើយតបនឹងប្រជាជន ហើយមិនមែនឆ្លើយតបនឹងអ្នកដែលបញ្ចុះបញ្ចូលនោះទេ។*

"លទ្ធិប្រជាធិបតេយ្យ ត្រូវតែមានជីវិត និងត្រូវបានអនុវត្តជារៀងរាល់ថ្ងៃ។ លទ្ធិប្រជាធិបតេយ្យ មានសេចក្ដីបរិយាយលម្អិតច្រើនលើសពីការដែលគ្រាន់តែបោះឆ្នោតតាមកាលកំណត់ ដែលក្នុងករណីជាច្រើន គឺគ្រាន់តែធ្វើឲ្យត្រូវតាមបែបបទប៉ុណ្ណោះ ដោយអវត្តមានឥទ្ធិពលសាធារណៈស្ដីពីការជ្រើសរើសបេក្ខជន និងលទ្ធភាពកម្រនៃការផ្លាស់ប្ដូរគោលនយោបាយ។ លទ្ធិប្រជាធិបតេយ្យ សំដៅដល់ទំនាក់ទំនងគ្នាពិតប្រាកដរវាងឆន្ទៈប្រជាជន និងច្បាប់ ព្រមទាំងគោលនយោបាយនានា ដែលប៉ះពាល់ដល់ពួកគេ ទោះជាច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្ដី។

កាន់តែច្រើនឡើងៗ "ប្រជាធិបតេយ្យបែបតំណាង" បានធ្វើឲ្យម្ចាស់ឆ្នោតមានការខកចិត្ត ពីព្រោះតែតំណាង រាស្ត្រ នៅពេលបានជាប់ឆ្នោតហើយ កម្រនឹងពិគ្រោះយោបល់ជាមួយម្ចាស់ឆ្នោតរបស់ខ្លួនណាស់ ហើយមានពេលខ្លះ ធ្វើការសម្រេចចិត្តផ្ទុយស្រឡះពីបំណងប្រាថ្នាដែលម្ចាស់បោះឆ្នោតចង់បាន។ ការដាច់ទំនាក់ទំនងគ្នាជាញឹកញយរវាងសភា និងប្រជាជន បាននាំឲ្យបាត់បង់សិទ្ធិបោះឆ្នោតនៅក្នុងប្រទេសជាច្រើន ដែលបណ្ដាលឲ្យមានការព្រងើយកន្តើយ ភាពអវត្តមាន និងការមិនទុកចិត្ត។ ការមិនពេញចិត្តចំពោះការងាររបស់សភា បានបើកច្រកឲ្យមានការកេងប្រវ័ញ្ចពីបញ្ហាសង្គម ដោយអ្នកនយោបាយដែលទាញយកប្រជាប្រិយភាពពីប្រជាជន។

ប្រជាធិបតេយ្យបែបតំណាង អាចចាត់ទុកជា "ប្រធិបតេយ្យ" ទៅបានលុះត្រាតែតំណាងរាស្ត្រទាំងនោះប្រាប់ម្ចាស់ឆ្នោតឲ្យដឹងជាមុនអំពីច្បាប់ និងសន្ធិសញ្ញាផ្សេងៗ ដែលនឹងអាចប៉ះពាល់ដល់ពួកគេ ពិគ្រោះយោបល់ជាមួយពួកគាត់ឲ្យបានទៀងទាត់ និងខិតខំព្យាយាមអនុវត្តឆន្ទៈរបស់ពួកគាត់ ដោយសុទ្ធចិត្ត។ យើងអាចគិតពីច្បាប់ និងសន្ធិសញ្ញាជាច្រើន រាប់ទាំងសន្ធិសញ្ញាធំៗកម្រិតតំបន់ ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងការចរចានៅឡើយ ដូចជា ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ភាពជាដៃគូវិនិយោគ និងពាណិជ្ជកម្មអន្តរអាត្លង់ទិក (TTIP) កិច្ចព្រម

ព្រៀងទូលំទូលាយ ផ្នែកពាណិជ្ជកម្ម និងសេដ្ឋកិច្ចអឺរ៉ុប-កាណាដា (CETA) និងកិច្ចព្រមព្រៀងសេវាកម្មដោះដូរពាណិជ្ជកម្ម (TISA) ដែលប្រាកដជានឹងត្រូវបានច្រានចោល ប្រសិនជាដាក់ឲ្យបោះឆ្នោតធ្វើប្រជាមតិ។ យ៉ាងហោចណាស់ ប្រជាធិបតេយ្យតម្រូវឲ្យមានការលាតត្រដាងទាំងស្រុង និងការចូលរួមពីពហុភាគីពាក់ព័ន្ធ ឧទាហរណ៍ "លទ្ធិប្រជាធិបតេយ្យដែលមានការចូលរួម"។ ប្រសិនបើមិនមានការយល់ព្រមពីប្រជាជន គឺមិនអាចគិតដល់តំណាងរាស្ត្រជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ ដើម្បីផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងបែបនេះឡើយ។

សភាដែលមិនតំណាងពិតប្រាកដ នឹងត្រូវបាត់បង់ភាពស្របច្បាប់របស់ខ្លួន កាលបើគ្រាន់តែធ្វើអ្វីដែលខ្លួនចង់ធ្វើសម្រាប់រយៈពេល x ឆ្នាំ តែបែរមិនឆ្លុះបញ្ចាំងពីឆន្ទៈរបស់ម្ចាស់ឆ្នោតនោះ។ នៅប្រទេសមួយចំនួន គេអាចនិយាយពីបាតុភូតនៃ "ការប្រើប្រាស់អំណាចផ្តាច់ការសភា" ដោយសារតែច្បាប់ និងសន្ធិសញ្ញា ត្រូវបានអនុម័តដោយមិនគិតគូរពីបំណងប្រាថ្នារបស់ម្ចាស់ឆ្នោត ដែលរហូតឈានដល់កម្រិតសង្គ្រោមឈ្លានពានប្រឆាំងយ៉ាងច្បាស់នឹងបំណងប្រាថ្នារបស់ប្រជាជន។

លទ្ធិប្រជាធិបតេយ្យតម្រូវឲ្យមានការគោរពសិទ្ធិទទួលព័ត៌មាន សេរីភាពនៃគំនិត និងការសម្តែងមតិ ដូចមានចែងក្នុងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាល (ICCPR) និងការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ នៅក្នុងការធ្វើការសម្រេចផ្សេងៗមានចែងក្នុងមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាល (ICCPR) ។

ការជាប់ទាក់ទងគ្នារវាងគោលនយោបាយ និងផលប្រយោជន៍សាធារណៈ ដែលប៉ះពាល់ដល់ពួកគេ ត្រូវបានធានាគត់មត់បំផុត តាមរយៈយន្តការប្រជាធិបតេយ្យដោយផ្ទាល់ នៃគំនិតផ្តួចផ្តើមជាសាធារណៈ និងការធ្វើប្រជាមតិ។ លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ គឺពិតជាផ្នែកមួយនៃវិធីសាស្ត្រដែលមានប្រសិទ្ធភាព អាចជឿទុកចិត្តបាន និងមានតម្លាភាពបំផុត ក្នុងការកំណត់ឆន្ទៈរបស់ប្រជាជន។ ដើម្បីបង្កើតការផ្លាស់ប្តូរតាមបែបប្រជាធិបតេយ្យ គេត្រូវតែគោរពសិទ្ធិមនុស្ស ជាពិសេស ពហុនិយម គោលការណ៍ច្បាប់បោះឆ្នោត សេរីភាពនៃគំនិត និងការសម្តែងមតិ សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពក្នុងការបង្កើតសមាគម។

ការលេចឡើងនៃអំណាចប្រជាជន គឺជាឱកាសមួយល្អបំផុត ដើម្បីនាំទៅរកការផ្លាស់ប្តូរ ដែលនឹងធានាសិទ្ធិមនុស្សសម្រាប់ជនគ្រប់រូប។ បុគ្គល និងក្រុមកាន់តែជាច្រើនឡើងៗថែមទៀត នឹងចេញដើរតាមដងផ្លូវនានា ដើម្បីទាមទារឲ្យមានការចូលរួមកាន់តែច្រើនពីសាធារណៈជន និងមានតម្លាភាព និងគណនេយ្យភាពខ្ពស់ជាងនេះថែមទៀត ពីសំណាក់អ្នកកាន់អំណាច - ចាប់ពីកម្រិតរដ្ឋាភិបាល រហូតដល់កម្រិតស្ថាប័នមិនមែនរដ្ឋ រាប់ទាំងវិស័យឯកជនផងដែរ។

ផលប្រយោជន៍ពិសេស ដូចជា ផលប្រយោជន៍នៃសាជីវកម្មរំលងជាតិ ធនាគារហិរញ្ញវត្ថុ ឬគ្រឹះស្ថានឧស្សាហកម្មយោធា ត្រូវតែបញ្ឈប់ការប្រើប្រាស់ឥទ្ធិពលមិនសមាមាត្រលើគោលនយោបាយក្នុងស្រុក និង

បរទេស ដែលជាញឹកញយ ផ្ទុយនឹងផលប្រយោជន៍សាធារណៈ។

ប្រជាធិបតេយ្យដោយផ្ទាល់ មានការចូលរួម និងមានការឆ្លើយតប បានបង្ហាញពីភាពអំណោយផលដល់ការសម្រេចបាននូវសណ្តាប់ធ្នាប់ពិភពលោកមួយដែលកាន់តែមានយុត្តិធម៌ថែមទៀត។ មានតែវិធីបែបនេះទេ ដែលនឹងអនុញ្ញាតឲ្យមានដំណើរវិវឌ្ឍន៍ពីសង្គមដែលកេងប្រវ័ញ្ចគ្នាទៅសង្គមផ្អែកលើការគោរពសិទ្ធិមនុស្ស”៕

# ចប់

*លោក អាលហ្វ្រិដ ដឺ ហ្សាយ៉ាស់ (Mr. Alfred de Zayas) (សហរដ្ឋអាមេរិក) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស តែងតាំងជាអ្នកជំនាញការឯករាជ្យលើកដំបូង ទទួលបន្ទុកសណ្តាប់ធ្នាប់អន្តរជាតិប្រកបដោយសមធម៌ និងប្រជាធិបតេយ្យ ដែលមានប្រសិទ្ធភាពចាប់ពីខែឧសភា ឆ្នាំ ២០១២ មក។ បច្ចុប្បន្ននេះ លោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិ នៅសាលាការទូតទីក្រុងហ្សឺណែវ ។ លោក ដឺ ហ្សាយ៉ាស់ បានប្រកបវិជ្ជាជីវៈ ច្បាប់សាជីវកម្ម និងច្បាប់គ្រួសារ នៅទីក្រុងញូវយ៉ក និងនៅរដ្ឋផ្លរីដា។ ក្នុងនាមលោកជាអ្នកកាន់អាណត្តិរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លោកស្ថិតនៅឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ និង បម្រើការក្នុងសមត្ថភាពរបស់បុគ្គលលោកផ្ទាល់។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់៖ http://www.ohchr.org/EN/Issues/IntOrder/Pages/IEInternationalorderIndex.aspx*

*ក្រុមអ្នកជំនាញការឯករាជ្យ គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប គឺជាឈ្មោះទូទៅនៃយន្តការឯករាជ្យរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ទទួលបន្ទុកឃ្លាំមើលនិងស្វែងរកការពិត ដែលដោះស្រាយទាំងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយៗជាក់លាក់ ទាំងបញ្ហាតាមវិស័យនៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក។ អ្នកជំនាញរបស់នីតិវិធីពិសេស "ធ្វើការឈរលើគោលការណ៍ស្ម័គ្រចិត្ត ពួកគេមិនមែនជាបុគ្គលិករបស់ អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគេធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពរបស់បុគ្គលពួកគេផ្ទាល់។*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក៖ លោក ធីបូត ហ្គីល្លែត តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣ ៨៩ ឬ អ៊ីម៉ែល tguillet@ohchr.org) ឬសរសេរមកកាន់៖ ie-internationalorder@ohchr.org*

***លោក/អ្នក អាចចូលទៅកាន់សេចក្តីប្រកាសព័ត៌មាននេះ តាមរយៈ៖***
*http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=20482&LangID=E*

**សម្រាប់ព័ត៌មានលើវិបសាយ និង បណ្តាញសង្គមរបស់អ្នក៖** ខ្លឹមសារពហុព័ត៌មាន & សារគន្លឹះៗទាក់ទងនឹងប្រកាសព័ត៌មានរបស់យើងមាននៅលើឆាណែលបណ្តាញសង្គមសិទ្ធិមនុស្ស អ.ស.ប មានរាយឈ្មោះដូចខាងក្រោម។ សូម ថេក ( tag) មកយើងដោយប្រើចំណុចទាញត្រឹមត្រូវ៖

ហ្វេសប៊ុក៖@UNHumanRights
ទ្វីតធឺ៖unitednationshumanrights
Instagram: unitednationshumanrights
ហ្គោហ្គឹល៖ Google+: unitednationshumanrights
យូធូប៖unohchr